# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

**គណៈគ្រូពេទ្យកម្ពុជា**
**ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ**

លេខ ០៤២/២១ ក.គ.ជ

ថ្ងៃព្រហ. ១៥កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១

# សេចក្តីណែនាំ
## ស្តីពី
## ការទិញ ឬជួលលំនៅដ្ឋានដើម្បីធ្វើជាការិយាល័យរបស់ក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានី-ខេត្ត

យោងសេចក្តីត្រូវការចាំបាច់របស់ក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានី-ខេត្តដែលត្រូវមានទីតាំងធ្វើការសមរម្យ ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិសូមលើកទឹកចិត្តឱ្យក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានី-ខេត្តសហការល្អជាមួយមន្ទីរសុខាភិបាលក្នុងការផ្តល់ទីតាំងក្នុងមន្ទីរតែម្តងដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការប្រតិបត្តិការ ដោយមន្ត្រីភាគច្រើនសុទ្ធសឹងជាមន្ត្រីរបស់មន្ទីរសុខាភិបាល ស្ថិតក្នុងហេតុផលនេះបើមន្ទីរមិនមានលទ្ធភាពផ្តល់ទំហំសម្រាប់ការិយាល័យទាំងមូលបានត្រឹមផ្នែកណាមួយនៃការិយាល័យក៏ជាការល្អដែរ។ ក្នុងករណីជៀសមិនរួចដែលតម្រូវឱ្យក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានី-ខេត្ត រកទីតាំងស្ថិតក្នុងភូមិសាស្ត្រណាមួយ ក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានី-ខេត្តត្រូវគោរពគោលការណ៍មួយចំនួនដូចខាងក្រោម៖

១-ត្រូវមានហេតុផលសមស្របការដែលមិនអាចមានទីតាំងការិយាល័យឋិតក្នុងមន្ទីរសុខាភិបាល។

២-ត្រូវមានការស្របមតិពីក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានី-ខេត្តសាមី។

៣-ត្រូវមានការអនុញ្ញាតិពីក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ។

៤-ត្រូវជ្រើសរើសទីតាំង និងសំណង់ដែលមានតម្លៃសមរម្យ និងមានភាពងាយស្រួលសម្រាប់បុគ្គលិក និងមន្ត្រីក្រុមប្រឹក្សាមកបំពេញការងារប្រចាំថ្ងៃ។

៥-មិនប៉ះពាល់ដល់ការចាត់ចែងហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា៣៥នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈគ្រូពេទ្យ និងសេចក្តីសម្រេចនៃការគ្រប់គ្រងហិរញ្ញវត្ថុចុះលេខ ០៦៧/២១ ក.គ.ជ ។

៦-មិនអនុញ្ញាតឱ្យមានបំណុលទោះស្ថិតក្នុងរូបភាពណា ឬទំហំប៉ុណ្ណាក៏ដោយ។

៧-ត្រូវបង្ហាញថាមានលទ្ធភាពហិរញ្ញវត្ថុ(បង្ហាញតារាងចំណូលចំណាយរួមទាំងសមតុល្យប្រចាំខែ/ឆ្នាំរយៈបីឆ្នាំចុងក្រោយ ព្រមទាំងឯកសារទាំងឡាយដែលពាក់ព័ន្ធនិងស្ថានភាពហិរញ្ញវត្ថុ តាមការកំណត់របស់គណៈកម្មការហិរញ្ញវត្ថុ)។

៨-ត្រូវបង្ហាញឯកសារលម្អិតដល់ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ក្នុងករណីដែលទទួលអំណោយពីស្ថាប័នមិនមែនរាជរដ្ឋាភិបាល។

**សាស្ត្រាចារ្យវេជ្ជ. ឆា គ្រួយ**

ក្នុងបរិវេណ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល អាសយដ្ឋាន លេខ៧៣ មហាវិថីព្រះមុនីវង្ស (ផ្លូវ ៩៣) សង្កាត់ ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទការិយាល័យ: (+៨៥៥) ២៣ ៩០០ ០០៩ អ៊ីម៉ែល: medicalcouncilofcambodia@gmail.com Facebook Page: គណៈគ្រូពេទ្យជាតិកម្ពុជា